ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៥

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែ ឧសភា ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យអាស៊ីដ | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | ៣ |
| ៣- | កិច្ចប្រជុំសារឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាសម្រាប់មនុស្សចាស់កម្ពុជា | ៥ |
| ៤- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១ | ៦ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

## សេចក្តីព្រាងច្បាប់ស្តីពី

# ការត្រួតពិនិត្យអាស៊ីដ

កាលពីថ្ងៃទី១១ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **កែវ ទិចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ខៀវ សាម៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យអាស៊ីដ ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងមហាផ្ទៃ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ការប្រើប្រាស់អាស៊ីដជាអាវុធដើម្បីជះទៅលើមនុស្សកើតមានជាបន្តបន្ទាប់ ដែលចាត់ទុកជាបទល្មើសសាហាវយង់ឃ្នងអមនុស្សធម៌ ជាសោកនាដកម្មមួយធ្វើឱ្យជនរងគ្រោះទទួលរងរបួសស្នាម ពិការទាំងផ្លូវកាយនិងផ្លូវចិត្ត ក្លាយជាជនពិការមួយរយៈ ឬពិការអស់មួយជីវិត ឬបណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិតក៏មាន។ លើសពីនេះទៅទៀត ជនពិការដែលរងគ្រោះដោយអាស៊ីដនេះ អាចបាត់បង់ការងារដោយសារពិការភាពរបស់ខ្លួន ជួនកាលធ្វើឱ្យអ្នកផងទាំងពួងស្អប់ខ្ពើម និងមានការរើសអើងទៀតផង។

ទោះបីជាព្រះរាជាណាចក្រកម្ពុជា មានក្រមព្រហ្មទណ្ឌសម្រាប់ផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗក៏ដោយ ក៏ជនល្មើសនៅតែមិនខ្លាចញញើតក្នុងការប្រព្រឹត្តបទល្មើសដដែល ដោយប្តូរគ្រប់រូបភាព ក្នុងសកម្មភាពប្រព្រឹត្តបទល្មើស ដូចជា បទល្មើសជះទឹកអាស៊ីដលើជនណាម្នាក់ ដែលជាប្រភេទបទល្មើស ប្រើប្រាស់អាវុធគ្មានសម្លេង ងាយស្រួលដល់ជនល្មើសធ្វើសកម្មភាពជាដើម។



ដោយមើលឃើញថា អំពើល្មើសនេះមានចរិតឃោរឃៅ អមនុស្សធម៌ បង្កការគំរាមគំហែងដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងសុវត្ថិភាពសង្គម និងដោយព្រះរាជាណាចក្រកម្ពុជាយើងមិនទាន់មានបទប្បញ្ញត្តិណាដោយឡែកសម្រាប់គ្រប់គ្រងអាស៊ីដ ទើបក្រសួងមហាផ្ទៃបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យអាស៊ីដ ក្នុងគោលបំណងកំណត់អំពីការគ្រប់គ្រងអាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយហេតុថា ក្រមព្រហ្មទណ្ឌដែលទើបតែ

ចូលជាធរមានថ្មីៗនេះ មិនបានចែងឱ្យបំទៅលើបទល្មើសដែលកើតឡើងពីការប្រើប្រាស់អាស៊ីដនេះទេ[១]។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលចំណងជើងទៅជា **ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង** ដើម្បីឱ្យស្របទៅនឹងខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ និងកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យអាស៊ីដ។

## សេចក្តីព្រាងច្បាប់ស្តីពី

# លទ្ធកម្មសាធារណៈ



កាលពីថ្ងៃទី២៥ និងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងឆ្នាំ១៩៩៥ លទ្ធកម្មសាធារណៈនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងនិងគ្រប់គ្រងតាមរយៈអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈក្រោមហិរញ្ញប្បទានសហប្រតិបត្តិការផ្នែកបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រកាសលេខ៣១៩ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងលទ្ធកម្មសាធារណៈ ហើយត្រូវបានចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ១៩៩៦ មក។ នៅឆ្នាំ២០០៥ ស្របតាមគោលនយោបាយកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ០៤៥ សហវ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ ដោយបង្កើនកម្រិតទឹកប្រាក់ទទួលខុសត្រូវជូនលទ្ធកម្មក្រសួង ស្ថាប័ន ខេត្ត ក្រុង សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ក្នុងការសម្រេចកិច្ចលទ្ធកម្មសាធារណៈ។

ក្នុងក្របខណ្ឌនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានហិរញ្ញប្បទានសហប្រតិបត្តិការផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍ ពិសេសពីធនាគារពិភពលោក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើវិសោធនកម្ម អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ខាងលើ ទៅជាអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ និងបានកែលម្អឡើងវិញនូវវិធាននិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដោយបានចងក្រងជាសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាននិងបទប្បញ្ញតិស្តីពីលទ្ធកម្មសាធារណៈ ហើយ ត្រូវបានដាក់ឱ្យអនុវត្តនៅពាក់កណ្តាលឆ្នាំ២០១០ តាមរយៈប្រកាសលេខ២៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥

ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

តាមរយៈការកែលម្អជាបន្តបន្ទាប់នូវបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ព្រមទាំងការធ្វើវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈខាងលើនេះ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា កាន់តែមានភាពរលូននិងល្អប្រសើរជាងមុន។ ប៉ុន្តែដោយការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជារហូតមកដល់ពេលនេះ មានរយៈពេលជាង ១៥ឆ្នាំ ដែលជារយៈពេលវែង ទាមទារនូវការពិនិត្យកែលម្អ បំពេញបន្ថែមថែមទៀតឱ្យបានសមស្របតាមការវិវត្តរបស់ប្រទេស និងសាកលលោក ដោយត្រូវរៀបចំតាក់តែងចងក្រងជាច្បាប់ដែលជាឧបករណ៍គតិយុត្តកម្រិតខ្ពស់ដ៏រឹងមាំ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក្នុងគោលបំណងធានាឲ្យប្រព័ន្ធលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាន់តែមានភាពរឹងមាំគ្រប់ជ្រុងជ្រោយ និងធានានូវរាល់កិច្ចលទ្ធកម្មសាធារណៈត្រូវបានអនុវត្តតាមប្រព័ន្ធតែមួយ ប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ ប្រសិទ្ធភាព និងការសន្សំសំចៃ(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ហើយបានសម្រេចដូចខាងក្រោម៖

១-ព្យួរទុកពាក្យ "**លទ្ធកម្ម**" ពិភាក្សានៅពេលក្រោយ។

២-បង្កើតក្រុមការងារប្រជុំចង្អៀតលើទម្រង់ច្បាប់ និងបន្តប្រជុំជំនាញបច្ចេកទេសតាមធម្មតា។

៣-មាត្រា៦ ព្យួរទុកកែសម្រួលពេលក្រោយ ព្រោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតែនាយកដ្ឋានលទ្ធកម្ម ពុំទាន់មានអគ្គនាយកដ្ឋានលទ្ធកម្មនៅឡើយ។

៤- ព្យួរទុកពាក្យ "**ស្ថាប័ន**" ដើម្បីស្នើសុំការសម្រេចពីថ្នាក់លើ ពីព្រោះពាក្យនេះ គេច្រើនប្រើសំដៅតែទៅលើក្រសួង។ ក្រៅពីនេះ អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិភាក្សាដល់ជំពូកទី៣៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី កំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

## កិច្ចប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើតគណៈកម្មាធិការជាតិកម្ពុជា សម្រាប់មនុស្សចាស់កម្ពុជា

កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ប្រាក់ សិទ្ធិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាសម្រាប់មនុស្សចាស់កម្ពុជា** ដោយមានការអញ្ជើញចូលរួមប្រជុំពីសំណាក់តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



សូមរំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាសម្រាប់មនុស្សចាស់កម្ពុជា បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេសលើកដំបូងនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១។ អង្គប្រជុំពេលនោះបានសម្រេចបង្កើតក្រុមការងារបង្កៀត ដើម្បីជួយពិនិត្យកែសម្រួលទម្រង់ឱ្យសមស្របតាមទម្រង់សម្រាប់ការកសាងលិខិតបទដ្ឋានគតិយុត្តនានា ដែលធ្លាប់អនុវត្តនិងខ្លឹមសារឡើងវិញ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងកែសម្រួលថ្មីនេះ ហើយបានសម្រេចលុបមាត្រា ២ ដែលនិយាយអំពីការបង្កើតទិវាមនុស្សចាស់ចោល ពីព្រោះសេចក្តីព្រាងអនុក្រឹត្យនេះ មិនមែនកំណត់ទិវាមនុស្សចាស់ទេ។

អង្គប្រជុំបានសម្រួលខ្លឹមសារនៅក្នុងមាត្រា៤ អំពីតួនាទីភារកិច្ចរបស់គណៈកម្មាធិការជាតិនេះ ឲ្យទទួលខុសត្រូវជាអ្នករៀបចំទិវាមនុស្សចាស់កម្ពុជាតែម្តង ដើម្បីជៀសវាងការបង្កើតអនុក្រឹត្យពីរដាច់ដោយឡែកពីគ្នា (អនុក្រឹត្យបង្កើតទិវាមនុស្សចាស់និងអនុក្រឹត្យបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ផង)។ ក្រៅពីនេះអង្គប្រជុំ បានសម្រេចកែសម្រួលខ្លឹមសារ ពិសេសអំពីរចនាសម្ព័ន្ធ និងប្រភពធនធាន ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១*



របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) លើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែមេសា ឆ្នាំ២០១១** នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឆៃលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ ក្នុងខែមេសានេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ១,១% ធៀបនឹងខែមុន និងកើនឡើង៥,២% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ ខែ)។ ក្នុងកំណើនសន្ទស្សន៍ថ្លៃ **មេសា/មីនា** មានការរួមចំណែកពីក្រុមម្ហូបអាហារ ៥០% ការដឹកជញ្ជូន ២៥% និងផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត ១៥ %។ ដូច្នេះគួរកត់សម្គាល់ថា ក្រុមទំនិញបីមុខនេះ បានរួមចំណែករហូតដល់ ៩០% ទៅលើសន្ទស្សន៍ថ្លៃសរុប។

➡ ថាមពល (ឧស្ម័ន សាំង និងម៉ាស៊ូត) ជាមុខទំនិញដែលមានការឡើងថ្លៃខ្លាំង និងជាមូលហេតុចំបងដែលជះឥទ្ធិពលលើការឡើងថ្លៃទំនិញ និងសេវាកម្មផ្សេងៗទៀត។ ថាមពលបានរួមចំណែក ២៩% ទៅលើការកើនឡើងនៃសន្ទស្សន៍ថ្លៃសរុប។

➡ កំណើនសន្ទស្សន៍ថ្លៃក្នុងខែមេសានេះ ជាអត្រាខ្ពស់បំផុតចាប់ពីចុងឆ្នាំ ២០១០ មក។ ក្រាហ្វ ១ បង្ហាញនិន្នាការផ្ទុយគ្នានៃសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១១ និង ២០១០ ដែលក្នុងឆ្នាំ ២០១០ សន្ទស្សន៍ថ្លៃមានការថយចុះក្នុងចន្លោះ មីនា–កក្កដា។

➡ ក្រុមទំនិញសំខាន់ៗ បើប្រៀបធៀបខែ(មេសា/មីនា) បង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ ម្ហូបអាហារ : +១,៣% | ( +៥,៨% ) | ▪ ភោជនីយដ្ឋាន : +០,៦% | ( +៨,២% ) |
| ▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធន : +០,៩% | ( +៤,៤% ) | ▪ ទំនិញ និងសេវាកម្មផ្សេងទៀត : +០,៨% | ( +៩,៦% ) |
| ▪ ការដឹកជញ្ជូន : +២,២% | ( +៧,៦% ) | | |

➡ ក្នុងក្រុមម្ហូបអាហារ ទំនិញប្រភេទសាច់បីមុខគឺ សាច់ជ្រូក សាច់គោ និងត្រីស្រស់ មានអត្រាថ្លៃកើនឡើងខ្ពស់លើសអត្រារួម ១,៣% របស់ក្រុមម្ហូបអាហារ។ មុខទំនិញបីមុខនេះ រួមចំណែក ៤២% ទៅលើការកើនឡើងនៃសន្ទស្សន៍ថ្លៃសរុប។

**តារាង១ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០០៩–២០១១**

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | | | | | | | | | |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | | | | | | | | | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | -០,៧% |
| | ខែមុន | -១,៥% | -០,១% | ១,៣% | ១,០% | ១,០% | ១,៩% | ១,៤% | ០,៧% | ០,៥% | -០,៣% | -០,៦% | -០,១% | |

* ការវិភាគជាលាយលក្ខអក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះអ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។
* ពត៌មាន និងតួលេខពណ៌ បៃតង សំដៅលទ្ធផលល្អប្រសើរ និងពណ៌ ក្រហម សំដៅលទ្ធផលសម្រាប់ការប្រុងប្រយ័ត្ន
* ដើម្បីមានសង្គតិភាពជាមួយក្រមភាសាខ្មែរ សញ្ញាក្បៀសនៅក្នុងសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ដែលជា Excel) ដោយសារបញ្ហាបច្ចេកទេស សញ្ញាក្បៀសតាងឲ្យកំណាត់ខ្ទង់ពាន់ ឯសញ្ញាចុចតាងឲ្យទសភាគវិញ។

ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០—២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




➡ អត្រាប្តូរប្រាក់៖

| *ប្រភេទ* | *អត្រាប្តូរប្រាក់* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| រ/ដុល្លារ | ៤ ០២០រ/១ដុល្លារ | +០,៤% | −៤,៣% |
| រ/បាត | ១៣៤រ/១បាត | +១,៥% | +៣,១% |
| រ/ដុង | ០,១៩៦រ/១ដុង | +២,១% | −១១,៣% |
| បាត/ដុល្លារ | ២៩,៩បាត/១ដុល្លារ | −១,៤% | −៧,៥% |
| ដុង/ដុល្លារ | ២០ ៥០០ដុង/ដុល្លារ | −១,៩% | +៨,០% |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ **នាខែមេសា ឆ្នាំ២០១១នេះ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳ ***ចំណូលអនុវត្តបានចំនួន ៦៥៧,៧ ពាន់លានរៀល*** *(មធ្យមប្រចាំខែ ៩៤% នៃគម្រោង) ក្នុងនោះ* ***ចំណូលមូលធន ៦១,៥ ពាន់លានរៀល*** (មធ្យមប្រចាំខែ ១២៧% នៃគម្រោង) និង**ចំណូលចរន្ត ៥៩៦,១ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩១% នៃគម្រោង)។




ក្រាហ្វ ២. ចំណូលថវិកាជាតិ ២០១០–២០១១

↳ បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ**កើនឡើង ១៣% និងកើនឡើង ២៨% ក្នុងរយៈពេល ១២ខែ។ កំណើនចំណូលក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណូលចរន្តកើនឡើង ៤,៦% និងបើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណូលចរន្តកើនឡើង ២៨% ។

↳ ចំណែកឯចំណូលមូលធនកើនឡើង ៤២៨% បើធៀបនឹងខែមុន និងកើនឡើង ២៧% ក្នុងរយៈពេល ១២ខែ។

↳ ក្នុងចំណូលចរន្ត៖

✓ ចំណូលសារពើពន្ធកើនឡើង ២០% និងកើនឡើង ៣០% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណូលសារពើពន្ធក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណូលពន្ធដារ ដែលក្នុងនោះ ពន្ធលើប្រាក់ចំណេញកើនឡើង ១១៩% ស្មើនឹង ១០១ ពាន់លានរៀល។

✓ ចំណូលមិនមែនសារពើពន្ធថយចុះ ៥០% ប៉ុន្តែកើនឡើង ១៤% ក្នុងរយៈពេល ១២ខែ។ ការថយចុះនៃចំណូលមិនមែនសារពើពន្ធក្នុងខែនេះ បណ្តាលមកពីឯកជនភាវូបនីយកម្មថយចុះ ៩៣% ស្មើនឹង ៦១ ពាន់លានរៀល។

| **ក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | | **ក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ✓ ពន្ធ និងអាករគយ : −៣,១% | ( +១២%) | ✓ នេសាទ : −៣២% | (−៣១%) |
| ✓ ចំណូលពន្ធដារ : +៥៤% | ( +៤៩%) | ✓ រុក្ខាប្រមាញ់ : +១៣១% | (-៥១%) |
| ✓ ចំណូលសារពើពន្ធផ្សេងៗ : +៦,៨% | ( −៣១%) | ✓សម្បទានរ៉ែ : +៦៨% | (+១៧៤%) |
| | | ✓ អាកាសចរណ៍ស៊ីវិល : +១២០% | (+៩៣%) |
| | | ✓ ផលទុនទេសចរណ៍ : -១៩% | (+២១%) |
| | | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +២% | (+៧៩% ) |
| | | ✓ អាករស្នាក់ទូត (លិខិតឆ្លងដែន និងទិដ្ឋាការ) :+៧១% | (+៦៨% ) |
| | | ✓ ឯកជនភាវូបនីយកម្ម : -៩៣% | (+១៥% ) |

↳ ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៤១៥,០ពាន់លានរៀល (*ជាមធ្យមប្រចាំខែ ៤៨% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៨១% ស្មើនឹង ៣៣៧,១ ពាន់លានរៀល (*មធ្យមប្រចាំខែ ៧៥% នៃគម្រោង*) និង**ចំណាយមូលធន** មានចំនួន ១៩% ស្មើនឹង ៥៧,១ពាន់លានរៀល (*មធ្យមប្រចាំខែ ១៥% នៃគម្រោង*) ។

↳ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** ថយចុះ ៩% ប៉ុន្តែ កើនឡើង ៩% ក្នុងរយៈពេល១២ខែ។ ការថយចុះនៃចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្តថយចុះ ១៥% (រយៈពេល ១២ខែ : +៥%) និងចំណាយមូលធន*កើនឡើង ៣៦%* (រយៈពេល ១២ខែ: +៣៧%) ។

↳ *តុល្យភាពថវិកាជាតិនៃខែមេសានេះមានអតិរេកចំនួន ២៤២,៦ ពាន់លានរៀល* ។ នេះជាអតិរេកថវិកាជាតិ ៤ខែជាប់គ្នា ក្នុងឆ្នាំ ២០១១ នេះ។

## ៣) ស្ថានភាពរូបិយវត្ថុ និងអត្រាការប្រាក់

➡ ក្នុងខែមេសា ឆ្នាំ២០១១ ស្ថានភាពរូបិយវត្ថុមានលក្ខណៈដូចខាងក្រោម៖

↳ **រូបិយវត្ថុទូទៅ** $M_2$ មានចំនួន ***២១ ០៦៨ពាន់លានរៀល*** កើនឡើង ៣,៩% ធៀបនឹងខែមុន និងកើនឡើង ១៨,២% ក្នុងរយៈពេល ១២ខែ។ កំណើន $M_2$ ធៀបនឹងខែមុនបណ្តាលមកពីរូបិយវត្ថុ $M_1$ កើនឡើង ៣,៤% (រយៈពេល ១២ខែ : +១២,៧%) និងរូបិយវត្ថុផ្សេងៗ កើនឡើង ៤,០% (រយៈពេល ១២ខែ : +១៩,៤%)។

↳ យោងតាមតួលេខសមាសធាតុរូបិយវត្ថុ នាពេលបច្ចុប្បន្ន ប្រាក់រៀលក្នុងសេដ្ឋកិច្ចមានចំនួន១៩% នៃរូបិយវត្ថុសរុប និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួនរហូតដល់ ៨១%។




ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ មេសា ២០១១

**ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល១២ខែ**

| | | |
|---|---|---|
| **$M_2$**<br>+៣,៩% (+១៨,២%) | **$M_1$**<br>+៣,៤% (+១២,៧%) | រូបិយវត្ថុក្រៅធនាគារ : +៣,១% (+១៤,១%)<br>ប្រាក់បញ្ញើចរន្ត : +១៣,៨% (–១៥,២%) |
| **= M1 + Quasi-money** | រូបិយវត្ថុផ្សេងៗ **(Quasi-money)** +៤,០%<br>(+១៩,៤%) | ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ : +២,៥% (+១៧,៣%)<br>ប្រាក់បញ្ញើជារូបិយបណ្ណ : +៤,០% (+១៩,៥%) |

↳ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២ ៨២៦លានដុល្លារ** *កើនឡើង ៤,៧%* បើធៀបនឹងខែមុន និងកើនឡើង ១៧,៥% ក្នុងរយៈពេល ១២ខែ។

↳ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** មានចំនួន **៧ ២៩១ ពាន់លានរៀល** កើនឡើង ៤,១%បើធៀបនឹងខែមុន និងកើនឡើង ៧,៤% ក្នុងរយៈពេល ១២ខែ។

↳ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** ជារួមមានការកើនឡើង ដោយឡែកក្នុងខែមេសានេះ មានចំនួន ១៤ ០៩៥ ពាន់លានរៀល កើនឡើង ១,៨% បើធៀបនឹងខែមុន និងកើនឡើង ២៤,៤% ក្នុងរយៈពេល ១២ខែ។

↳ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** : ខែនេះមិនទាន់មានតួលេខ។

↳ ***អត្រាការប្រាក់ប្រចាំឆ្នាំ៖***

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥៣% | 0% | –0,៨% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ២២,៤៧% | –0,៣% | –២,0% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៥% | –0,២% | –៩,៨% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៦,២៤% | +២,១% | +0,១ |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែមេសា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

↳ កសិកម្ម៖

✓ ផលិតកម្មនេសាទមាន **៣៥ ពាន់តោន** ថយចុះ ៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ។

↳ ឧស្សាហកម្ម៖

✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២០៦លានគីឡូវ៉ាត់ម៉ោង ថយចុះ ៤% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១០% ក្នុងរយៈពេល ១២ខែ។

– អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ០,៧លានគីឡូវ៉ាត់ម៉ោង ថយចុះ ៥% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥២% ក្នុងរយៈពេល ១២ខែ។

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន២៥៩ លានដុល្លារ កើនឡើង២៥%និងកើនឡើង២៤%ក្នុងរយៈពេល ១២ខែ។

✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស៖

| ប្រភេទ | ចំនួន—មេសា២០១១ | ចំនួន—មីនា២០១១ | ចំនួន—មេសា២០១០ |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៩ | ៨ | ២ |
| ▪ ឧស្សាហកម្មធុនតូច និងសប្បកម្ម (បើកថ្មី) | ១៣ | ៤៦ | ៥ |
| ▪ ឧស្សាហកម្មធុនតូច និងសប្បកម្ម (បន្ត) | ១២ | ១៦ | ១២ |

➡ សំណង់៖

↳ **សំណង់អនុញ្ញាតឲ្យសាងសង់** មានចំនួន ៥៣០,៤ពាន់ម៉ែ$^{២}$ កើនឡើង៤៣% បើធៀបនឹងខែមុន និង កើនឡើង ៦០៧% ក្នុងរយៈពេល ១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ១៥៧,២លានដុល្លារ កើនឡើង ២៤% បើធៀបនឹងខែមុន និងកើនឡើង ៥៣៨% ក្នុងរយៈពេល ១២ខែ។

↳ **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ ឧស្សាហកម្ម (៦៧%នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និង**លំនៅឋាន** (២៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

| ប្រភេទ | ផ្ទៃក្រឡា ពាន់ម៉ែ$^{២}$ —មេសា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ ឧស្សាហកម្ម | ៣៥៤,៨ | +៣៧៧% | +៦៨៧៤% |
| ▪ លំនៅឋាន | ១២៧,៣ | –៤៨% | +១៣០% |
| ▪ សំណង់អនុញ្ញាតសរុប | ៥៣០,៤ | +៤៣% | +៦០៧% |

➡ **ការងារ៖**

| ប្រភេទ | ចំនួន—មេសា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៣ ៨៥០ | +១០២% | 0 |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣ ៨៧៣ | +១៨៦% | +៣០% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១ ៤៨៩ | +៥៨៣% | +៣៣% |
| អ្នកទទួលបានការងារក្នុងប្រទេស | ២ ៣៨៤ | +១១០% | +២៩% |

➡ **វិនិយោគ៖**

↳ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មី និងពង្រីក) ក្នុងខែមេសា មានចំនួន៨ ។ គម្រោងទាំងនេះស្ថិតតែក្នុងវិស័យឧស្សាហកម្មប៉ុណ្ណោះ និងបើគិតជាទុនវិនិយោគស្មើនឹង **៣២,២លានដុល្លារ** បើធៀបនឹងខែមុន ថយចុះ ៣៦% ប៉ុន្តែកើនឡើង៨៦% ក្នុងរយៈពេល ១២ខែ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **១២ពាន់នាក់**។

➡ **សេវាកម្ម និងទេសចរណ៍៖**

↳ ការចុះបញ្ជី និងលុបចេញពីបញ្ជី

| ប្រភេទ | ចំនួន—មេសា២០១១ | ចំនួន—មីនា២០១១ | ចំនួន—មេសា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២០៣ | ២៩៥ | ២០៧ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤ | ៦ | 0 |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ២៨០ | ២៥៣ | ២១០ |

↳ **ទំនិញឆ្លងកាត់តាមផែ** (សរុប៦ផែ) មានចំនួន ៤០០,៥ ពាន់តោន ថយចុះ ១,៤% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ២៧% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលក្នុងរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ ផែភ្នំពេញ : +៦% | (+២៥%) | ▪ ផែឧកញ៉ាម៉ុង : -២៣,៧% | ( +៣៥%) |
| ▪ ផែកំពង់សោម : +៤% | ( +២៦%) | ▪ ផែស្រែអំបិល និងកោះកុង : –៥១% | (+៤៦%) |

↳ **ការហោះហើរតាមផ្លូវអាកាស និងទេសចរណ៍**

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៦,២ | –៣៨% | +៣% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៥,៨ | –១៦% | –៨៩% |
| ▪ ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស | មិនមានតួលេខ | មិនមានតួលេខ | មិនមានតួលេខ |
| ▪ ចំនួនអ្នកទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | មិនមានតួលេខ | មិនមានតួលេខ | មិនមានតួលេខ |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែមេសាមានចំនួន ២ ២២៩ពាន់លានរៀល កើនឡើង៩% បើធៀបនឹងខែមុន និងកើនឡើង ៣៣% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| ប្រេងសាំង | +១% | +៩% | ប្រេងខ្មៅ | –៥៥% | –៦២% |
| ប្រេងម៉ាស៊ូត | +៥% | +៩% | ដែកសំណង់ | –៥៤% | –៣៤% |
| គ្រឿងអេឡិចត្រូនិច | +១០% | +២៥% | ស៊ីម៉ង់ត៍ | –២៤% | –៥% |
| ស្រូវសាលី | +២២% | –៣៥% | រថយន្តសរុប (ពាន់លានរៀល) | –២០% | +២៤% |
| អង្ករ | +១៧% | –៥៧% | ត្រាក់ទ័រនិងគោយន្ត | –១៦% | +១៣២% |
| ផ្លែឈើ និងបន្លែ | +៨% | –៣% | ម៉ូតូ | –២៥% | –៣៥% |
| ជី និងថ្នាំកសិកម្ម | +១៧% | +៥៦% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | –៦% | +៩% |
| ភេសជ្ជៈ | +២៤៥% | +១៨៧% | | | |

➡**ការនាំចេញ** ក្នុងខែមេសា ឆ្នាំ២០១១ មានចំនួន ១ ៣៤៨ពាន់លានរៀល កើនឡើង ១%  ធៀបនឹងខែមុន និងកើនឡើង ៤២%  ក្នុងរយៈពេល ១២ខែ។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| វាយនភណ្ឌនិងស្បែកជើង | +២% | +៤៨% | អង្ករ | –៥% | +៣២១% |
| កៅស៊ូ | +២០% | +៥៨% | ផលិតផលនេសាទ | –៩% | –៩% |
| ផលិតផលឈើកែច្នៃ | –២២% | +៣០០៤% | | | |

➡ *ក្នុងខែមេសា ឆ្នាំ២០១១នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៨៨១ពាន់លានរៀល ស្មើនឹង ២១៩ លានដុល្លារ ស.រ.អ.។*

## ៦. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមេសា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | រយៈពេល ១២ខែ | កំណត់សម្គាល់ |
|---|---|---|---|
| ១.ថ្លៃប្រេងសាំង<br>ម៉ាស៊ូត<br>ឧស្ម័ន | +៤,៧%<br>+៤,៧%<br>+២,៩% | +១៦%<br>+២៥%<br>+២០% | ដាក់សម្ពាធលើ ការឡើងថ្លៃទំនិញប្រើប្រាស់ |
| ២.ពន្ធលើប្រាក់ចំណេញ | +១១៩% | +៩៥% | ធ្វើឲ្យចំណូលពន្ធដារធំជាងពន្ធ និងអាករគយក្នុងខែនេះ |
| ៣.សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ម៉ែ²) | +៤៣% | +៦០៧% | ជាទូទៅសំណង់លំនៅឋានធំៗនិងឧស្សាហកម្ម |
| ៤. គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. (ទុនវិនិយោគ) | -៣៦% | -៤៧% | លំហូរទុនវិនិយោគ អនុញ្ញាតដោយ គ.វ.ក./ក.អ.ក. នាខែនេះ មានតែក្នុងវិស័យឧស្សាហកម្មដដែលដូចខែមុន |

## ៧) ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ខែមេសា ឆ្នាំ២០១១ មានការកើនឡើងក្នុងកំរិតយ៉ាងខ្ពស់ ដែលជាចំបងបណ្តាលមកពីការឡើងថ្លៃសាច់ជ្រូក សាច់គោ និងត្រីស្រស់។ ការឡើងថ្លៃគួរឲ្យបារម្មណ៍នៃ ឧស្ម័ន ប្រេងសាំង និងម៉ាស៊ូត បានដាក់សម្ពាធបន្ថែមទៀតលើការឡើងថ្លៃទំនិញប្រើប្រាស់។

- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ខែមេសា ឆ្នាំ២០១១ បង្ហាញនិន្នាការកើនឡើង ខុសពីឆ្នាំ ២០១០ ដែលកាលនោះ សន្ទស្សន៍ថ្លៃចាប់ផ្តើមថយចុះពីខែមីនា រហូតដល់កក្កដា (បើប្រៀបធៀបខែដូចគ្នា)។
- មានការរំពឹងថាសន្ទស្សន៍ថ្លៃនឹងបន្តកើនឡើងទៀតក្នុងខែក្រោយ។

២) ចំណូលសារពើពន្ធក្នុងខែមេសានេះបង្ហាញថា ចំណូលពន្ធដារមានចំនួនលើសពន្ធ និងអាករគយ ដែលនេះជាព្រឹត្តិការណ៍មិនធ្លាប់មានពីមុនមក។

- យ៉ាងណាក្តី ការកើនឡើងគួរឲ្យចាប់អារម្មណ៍ នៃចំណូលពន្ធដារនាខែនេះ គឺដោយសារនីតិវិធីថ្មីសម្រាប់ក្រុមហ៊ុនក្នុងការទូទាត់បំណុលពន្ធលើប្រាក់ចំណេញឆ្នាំ២០១០ ដែលតម្រូវឲ្យក្រុមហ៊ុនទាំងអស់ ដែលជាប់កាតព្វកិច្ចពន្ធត្រូវដេម្រះបញ្ជីឲ្យអស់នៅត្រីមាសទី១ ដើមឆ្នាំ។ ដូចនេះហើយការទូទាត់នោះ បានហូរចូលក្នុងចំណូលខែមេសា។

៣. វិស័យសំណង់បន្តកើនឡើងគួរឲ្យកត់សម្គាល់ ដែលជារួមដោយសារសន្ទុះនៃការសុំអនុញ្ញាតសំណង់ធំៗ ដូចជា ខុនដូ និងរោងចក្រ ដែលភាគច្រើនស្ថិតនៅក្នុងក្រុង។

៤) មានថយចុះគួរឲ្យចាប់អារម្មណ៍ នៃអ្នកដំណើរអន្តរជាតិតាមផ្លូវអាកាស ។

### *ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម :*

១) ការឡើងថ្លៃជាប្រចាំនៃម្ហូបអាហារ ជាភស្តុតាងដែលតម្រូវឲ្យកម្ពុជាផ្តោតជាសំខាន់លើវិស័យកសិកម្ម។

- ត្រូវអភិវឌ្ឍវារីវប្បកម្មឲ្យបានលឿនបំផុត
- ត្រូវបង្កើតផលិតកម្មចំណីសត្វក្នុងស្រុក

២) ក្នុងទស្សនៈវិស័យនគរូបនីយកម្ម និងការអភិវឌ្ឍយូរអង្វែង គួរបញ្ឈប់ការអនុញ្ញាតឲ្យសាងសង់រោងចក្រនៅក្នុងក្រុង។ ការនេះក៏អាចកាត់បន្ថយលំហូរពលកម្មពីជនបទចូលក្រុង និងបង្រួមវិសមភាពរវាងទីក្រុង និងជនបទ។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០៥/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យបម្រើនព្រះជន្មវស្សាព្រះមុនីកោសល **ហ៊ុល សុវណ្ណ** ព្រះអនុគុណ ខណ្ឌឫស្សីកែវ និងជាព្រះចៅអធិការ វត្តទួលសុវណ្ណារាម ក្នុងគម្រប់ព្រះជន្ម ៨៧ ឈានចូល ៨៨ ព្រះវស្សា និងបុណ្យបញ្ចុះខណ្ឌសីមា ពុទ្ធាភិសេក សម្ពោធឆ្លងសមិទ្ធិផលនានា ក្នុងវត្តទួលសុវណ្ណារាម ហៅវត្តទួលសង្កែ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវត្តទួលសុវណ្ណារាម ហៅវត្តទួលសង្កែ។ |
| ២ | ០៥/០៥/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១១ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៥/០៥/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៦/០៥/១១<br>ម៉ោង ០៧ : ៥០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ាន លើកទី ១៨ នៅទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូនេស៊ី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៥ | ០៨/០៥/១១<br>ម៉ោង ១០ : ២០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរមាតុភូមិនិវត្តន៍ របស់គណៈប្រតិភូមកពីចូលរួមសន្និសីទ ស្ដីពីគ្រោះធម្មជាតិ និងការការពារបរិស្ថាន នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ដឹកនាំដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៦ | ០៩/០៥/១១<br>ម៉ោង ០៩ : ៣០ នាទី | ចូលរួមចុះពិនិត្យការដ្ឋានសាងសង់ អគារមជ្ឈមណ្ឌលតំកល់ឯកសារច្បាប់ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅរាជធានីភ្នំពេញ។ |
| ៧ | ០៩/០៥/១១<br>ម៉ោង ១៥ : ៣០ នាទី" | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ វាយតម្លៃទីក្រុងទឹកស្អាត។<br>២-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១ (បន្ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១០/០៥/១១<br>ម៉ោង ១០ : ០០ នាទី" | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ វាយតម្លៃទីក្រុងទឹកស្អាត។<br>២-សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ ។<br>៣-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។<br>៤-បញ្ហាផ្សេងៗ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១១/០៥/១១<br>ម៉ោង ០៨ : ៤០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារស្ថាប័នប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |
| ១០ | ១២/០៥/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមពិធីបញ្ចុះបឋមសិលា និងបើកការដ្ឋានសាងសង់អគារលក់សំបុត្រពេលថ្ងៃ នៃមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរ ខេត្តសៀមរាប-អង្គរ នៅមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរ ខេត្តសៀមរាប-អង្គរ។ |
| ១១ | ១៨/០៥/១១<br>ម៉ោង ០៩ : ៣០នាទី | ប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ម៉ម សុផាណា** អំពីប្លង់មេ នៃមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរខេត្តសៀមរាប នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៩/០៥/១១<br>ម៉ោង ០៩ : ៣០នាទី | ប្រជុំជាមួយលោក Jo Yong Su លេខាទី១ នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងក្រុមហ៊ុន Mansudae New Tech ដើម្បីពិភាក្សាការងារសាងសង់អគារសារៈមន្ទីរសព្វទស្សន៍ ខេត្តសៀមរាប នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៩/០៥/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងគោលនយោបាយជាតិ សុវត្ថិភាពចរាចរណ៍ផ្លូវគោក និងសេចក្ដីព្រាងផែនការសកម្មភាពជាតិទសវត្សរ៍ សុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ ២០១១-២០២០។<br>២-បញ្ហាផ្សេងៗ ។<br>សម្រាប់ត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ២០/០៥/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិ សុវត្ថិភាពចរាចរណ៍ផ្លូវគោក និងសេចក្តីព្រាងផែនការសកម្មភាពជាតិទសវត្សរ៍ សុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ ២០១១-២០២០។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីយោធិនជាប់កិច្ចសន្យា ។<br>៣-បញ្ហាផ្សេងៗ នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១៥ | ២៤/០៥/១១<br>ម៉ោង ១១ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយក្រុមការងារ K-CEK នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៦ | ២៤/០៥/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៧ | ២៧/០៥/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ÷<br>១-សេចក្តីព្រាងច្បាប់ ស្តីពីពន្ធនាគារ ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយ ចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ។<br>៣- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ។<br>៤-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៨ | ៣០/០៥/១១<br>ម៉ោង ០៨ : ៣០នាទី" | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៩ | ៣០/០៥/១១<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ២០ | ៣១/០៥/១១<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីពន្ធនាគារ ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយ ចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ។<br>៣- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ។<br>៤-បញ្ហាផ្សេងៗ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៨/០៥/១១ | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរមាតុភូមិនិវត្តន៍ របស់គណៈប្រតិភូមកពីចូលរួមសន្និសីទ ស្តីពីគ្រោះធម្មជាតិ និងការការពារបរិស្ថាន នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ដឹកនាំដោយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ២ | ១១/០៥/១១ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារស្ថាប័នប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសង្កាត់ផ្សាថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ |
| ៣ | ១៨/០៥/១១ | ចូលរួមប្រជុំពិភាក្សាជាមួយ លោក Kelly Birl, ADB Mission ស្តីពីគម្រោងវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៩-២០/០៥/១១ | ចូលរួមប្រជុំពិភាក្សាជាមួយ លោកស្រី Lindy Talja, ADB Analyst (Accounting and Management) ស្តីពីគម្រោងវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០៤/១១ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |

## ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ ( Panorama Museum ) ក្នុងខេត្តសៀមរាប រវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុន Mansudae New Tech Corporation Ltd ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ០៥ មេសា ២០១១



នៅក្នុងឱកាសនោះ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានមានប្រសាសន៍ថា៖ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចរៀបចំមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរ (Welcome Center) ដែលមានផ្ទៃដី ទំហំ 180m x 350m នឹងត្រូវសាងសង់នៅបូរីវប្បធម៌ និងទេសចរខេត្តសៀមរាប។ គោលបំណងដ៏សំខាន់នៃការបង្កើតមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរ (Welcome Center) នេះឡើង គឺដើម្បីផ្តល់នូវព័ត៌មានទាំងឡាយណាដែលទាក់ទងទៅនឹងប្រាសាទអង្គរវត្ត និងប្រាសាទផ្សេងៗមួយចំនួនទៀត ជូនភ្ញៀវទេសចរជាតិនិងអន្តរជាតិ ឲ្យបានយល់ដឹងពីអង្គរវត្តតាមរយៈមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរ (Welcome Center) នឹងជួយសម្របសម្រួលដល់ភ្ញៀវទេសចរមានអារម្មណ៍ងាយស្រួល និងប្រកបដោយផាសុកភាព ហើយមជ្ឈមណ្ឌលនេះ ជាកន្លែងចេញ-ចូលតែមួយ (One Stop Service) ផងដែរ។





ក្រោមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការជម្រុញ និងលើកទឹកចិត្តវិនិយោគ ក្រុមហ៊ុន Mansudae New Tech Corporation Ltd បានសម្រេចវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ (Panorama Museum) ក្នុងខេត្តសៀមរាប ជាមួយអាជ្ញាធរអប្សរា ក្រោមរូបភាពសាងសង់សហការនឹងផ្ទេរ ដែលមានទុនវិនិយោគចំនួន 15,253,320 USD ។ សារមន្ទីរនេះត្រូវសាងសង់នៅលើផ្ទៃដីប្រមាណ 600$m^2$ ក្នុងមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរសៀមរាប-អង្គរ ហើយអគារទំហំ 5409,77$m^2$ ។ ក្រុមហ៊ុមផលិតខ្សែភាពយន្ត 3D និងគូរផ្ទាំងគំនូរដែលពាក់ព័ន្ធនឹងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជាមួយដែលមានបណ្តោយប្រវែង 122,5m និងទទឹងប្រវែង 12,9m ដាក់តាំងបង្ហាញក្នុងសារមន្ទីរ ហើយផ្ទាំងគំនូរនេះនឹងក្លាយជាផ្ទាំងគំនូរដ៏ធំកម្រមាននៅក្នុងពិភពលោក រួមទាំងការរៀបចំមជ្ឈមណ្ឌលព័ត៌មានផងដែរ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារមន្ទីរនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជម្រុញវិស័យទេសចរណ៍បន្ថែមទៀតមកទស្សនាប្រទេសកម្ពុជា ៕

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | Ék]tþm Km sysamILn | អនុប្រធាន ក:ស:វ: |
| និពន្ធនាយក ៖ | Ék]tþm gan PrN | អគ្គលេខាធិការ ក:ស:វ: |
| វិភាគស្ថានភាពសេដ្ឋកិច្ច៖ | Ék]tþm Gm sT | សមាជិកបម្រុង ក:ស:វ: |
| និពន្ធអក្ខបទ ៖ | Ék]tþm eGg rtna | អគ្គលេខាធិការរង ក:ស:វ: |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | elak sy vasna | ប្រធានការិយាល័យ ក:ស:វ: |
| យកព័ត៌មាន និងថតរូប ៖ | elak ehg sP3bB | ប្រធានការិយាល័យ ក:ស:វ: |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | elak Gk Eda | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក:ស:វ: |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០
ទូរសារលេខ: ០២៣ ២១១ ៩៤៣
E-mail: veasna@live.in